រាជរដ្ឋាភិបាលកម្ពុជា & ស្ថានទូតអូស្ត្រាលី

# សេចក្តីប្រកាសពត៌មានរួម

## ប្រទេសអូស្ត្រាលីគាំទ្រដល់យុទ្ធសាស្ត្រកំណែទំរង់ច្បាប់និងតុលាការរបស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តកំពង់ធំ និង ខេត្តបន្ទាយមានជ័យ

អភិបាលខេត្តកំពង់ធំ និងអភិបាលខេត្តបន្ទាយមានជ័យ រួមជាមួយលោកស្រី អាទ្ធី ផាទែល (Arthi Patel) តំណាងទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៏អន្តរជាតិ(AusAID) បានចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចព្រមព្រៀង ដើម្បីគាំទ្រដល់ការអនុវត្តន៏កម្មវិធីកំណែទំរង់ច្បាប់និងតុលាការរបស់រាជរដ្ឋាភិបាលនៅខេត្តកំពងធំ និងខេត្តបន្ទាយមានជ័យ ។

ពិធីចុះហត្ថលេខានេះបានប្រារពនៅថ្ងៃទី១០ និង១១ ខែមិនា ឆ្នាំ២០០៩ ដែលមានវត្តមានជាសាក្សីដោយលោកជំទាវឯកអគ្គរាជទូតអូស្ត្រាលី **ម៉ាហ្គារេត អាដាមសុន** (Margaret Adamson) និងឯកឧត្តម **ព្រុំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងមានការចូលរួមដោយភ្ញៀវកិត្តយសនិងមន្ត្រីពីក្រសួងមហាផ្ទៃ ក្រសួងយុត្តិធមិ និងពីទីភ្នាក់ងារផ្សេងៗទៀតនៅថ្នាក់ខេត្ត ។ រដ្ឋាភិបាលអូស្ត្រាលីបានផ្តល់មូលនិធិដល់កម្មវិធីនេះតាមរយៈគម្រោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធមិនៅកម្ពុជា (CCJAP) ដំណាក់កាលទី៣ ។

នៅដំណាច់ខែធ្នូ ឆ្នាំ២០០៨ ព្រឹត្តិការណ៏នេះបានកើតឡើងនៅខេត្តបាត់ដំបង និងព្រៃវែង ហើយពេលនេះបានគូសបញ្ជាក់អំពីជំហានសំខាន់ផ្សេងមួយទៀតផងដែរ ចំពោះកិច្ចសហប្រតិបត្តការណ៏រវាងប្រទេសអូស្ត្រាលី និងប្រទេសកម្ពុជា ដើម្បីគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការពង្រឹងប្រព័ន្ធយុត្តិធមិនៅថ្នាក់ក្រោមជាតិ ។

គំរោងដំណាក់កាលទី៣នេះ ត្រូវបានរៀបចំឡើងដើម្បីពង្រឹងការកសាងសមត្ថភាពស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលពាក់ព័ន្ធនឹងវិស័យព្រហ្មទណ្ឌនិងយុត្តិធមិ ដើម្បីអនុវត្តយុទ្ធសស្ត្រកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធមិ ក៏ដូចជាកំណែទំរង់នានារបស់រាជរដ្ឋាភិបាលកម្ពុជា ដូចជាកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុ និងរដ្ឋបាលសាធារណៈ កំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ ។

លោកជំទាវឯកអគ្គរាជទូត ម៉ាហ្គារេត អាដាមសុន បានមានប្រសាសន៏ថា "មានពាក្យមួយឃ្លាដ៏ល្បីល្បាញនៅក្នុងប្រទេសអូស្ត្រាលីនិយាយថា យុត្តិធមិគឺមិនត្រឹមតែត្រូវបានអនុវត្តប៉ុណ្ណោះទេ ប៉ុន្តែការអនុវត្តការងារយុត្តិធមិក៏គួរត្រូវបានធ្វើឱ្យគេមើលឃើញផងដែរ ។ ដូច្នេះ ថ្ងៃនេះយើងមានវត្តមាននៅទីនេះ ដើម្បីធ្វើជាសាក្សីចំពោះអ្វី ដែលយើងជឿជាក់ថា ជាការចាប់ផ្តើមនូវគំរូនិងនិយាមថ្មីដើម្បីអនុវត្តការងារយុត្តិធមិនៅក្នុងប្រទេសកម្ពុជា" ។

ឯកឧត្តម ព្រំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានមានប្រសាសន៍ថា " គំរោងជំនួយយុត្តិធម៌ព្រហ្មទណ្ឌនៅកម្ពុជាដំណាក់កាលទី៣ ត្រូវបានអនុវត្តដោយមានកិច្ចសហការសម្របសម្រួលពីក្រុមគំរោង AusAID និងរាជរដ្ឋាភិបាលកម្ពុជា នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីកែលំអប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។ កិច្ចព្រមព្រៀងមានសារសំខាន់ណាស់សំរាប់ថ្នាក់ខេត្តដែលនឹងម្ចាស់ការ ទទួលខុសត្រូវលើកំណែទំរង់ជាគន្លឹះនៃប្រព័ន្ធយុត្តិធម៌ " ។

ឯកឧត្តម ណាំ ទុំ អភិបាលខេត្តកំពង់ធំ បានស្វាគមន៍ជំនួយរបស់ប្រទេសអូស្ត្រាលី និងបានមានប្រសាសន៍ថា "យើងមានជំនឿយ៉ាងមុតមាំថា ជំនួយដ៏មានសារសំខាន់នេះ នឹងពង្រឹងប្រព័ន្ធយុត្តិធម៌នៅស្ថាប័នពាក់ព័ន្ធថ្នាក់ខេត្ត ដែលនឹងបង្កើនការជឿទុកចិត្តនៃការគាំទ្រពីសហគមន៍ដើម្បីការអភិវឌ្ឍន៍ " ។

ឯកឧត្តម អ៊ុង អឿន អភិបាលខេត្តបន្ទាយមានជ័យ បានយល់ស្របនិងបានថ្លែងបញ្ជាក់ថា "ដើម្បីអោយសហគមន៍ទាំងមូល ទទួលបានសុវត្ថិភាព និងសន្តិសុខដោយមានភាពស្មើគ្នាចំពោះមុខច្បាប់ ទាមទារនូវការកែលំអចំពោះស្ថាប័នរដ្ឋនិងឯកជន ជាពិសេសលើវិស័យព្រហ្មទណ្ឌ និងយុត្តិធម៌ ដែលមាន នគរបាល តុលាការ ពន្ធនាគារ និងកងរាជអាវុធហត្ថ ព្រមទាំងអាជ្ញាធរដែនដី។ ការជួយគាំទ្រនេះមានសារសំខាន់ចាំបាច់សំរាប់ប្រជាជន និងប្រទេសកម្ពុជា " ។

ប្រទេសអូស្ត្រាលីបានផ្តល់ជំនួយគាំទ្រដល់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៅកម្ពុជា ចាប់តាំងពីឆ្នាំ១៩៩៧ តាមរយៈគម្រោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជារបស់ទីភ្នាក់ងារ AusAID ។ គំរោងជំនួយនេះ ត្រូវបានរៀបចំឡើងដើម្បីពង្រឹងប្រព័ន្ធព្រហ្មទណ្ឌនិងយុត្តិធម៌ដោយផ្តោតសំខាន់ទៅលើក្រុមជនងាយរងគ្រោះ រួមទាំងស្ត្រី និងអនិតិជនផងដែរ ។

**ទំនាក់ទំនងការផ្សាយ: លោកស្រី ហ៊ឹយុណា ខស្ស លេខាទី១**
**ទូរស័ព្ទលេខ: ០២៣ ២១៣ ៤៧០ ស្ថានទូតអូស្ត្រាលីនៅភ្នំពេញ**
**ថ្ងៃទី១០ ខែមិនា ឆ្នាំ២០០៩**

Villa 11, R.V. Senei Vinnavaut Oum (Former St 254), Chaktaumuk Quarter, Daun Penh District,
Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413